

ព័ត៌មានកម្មវិធី SPCR

# ការប្រែប្រួលអាកាសធាតុ

ADB

អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
កម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR)

នាយកដ្ឋានប្រែប្រួលអាកាសធាតុ
ខែមីនា ឆ្នាំ២០១៨ លេខ ១២

## ការពិគ្រោះយោបល់ផ្តល់អាទិភាពដល់គម្រោងការបន្សាំដើម្បីរៀបចំសំណើគម្រោង

នៅថ្ងៃទី២១ ខែមីនា ឆ្នាំ២០១៨ នាយកដ្ឋានប្រែប្រួលអាកាសធាតុ នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ស្តីពីការចាត់អាទិភាពគម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុចំនួន ៦(ខេត្តពោធិ៍សាត់ បាត់ដំបង កំពង់ឆ្នាំង កំពង់ធំ ព្រៃវែង និងត្បូងឃ្មុំ)។ សិក្ខាសាលានេះ ដឹកនាំដោយឯកឧត្តម ឯ វុឌ្ឍី អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព ក្រោមកិច្ចសហការជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងធនធានទឹក និងឧតុនិយម ក្រសួងបរិស្ថាន និងមន្ទីរពាក់ព័ន្ធ។

នាយកដ្ឋានប្រែប្រួលអាកាសធាតុ បានសម្របសម្រួលបង្កើតឱ្យមានការសិក្សាលទ្ធភាពដំបូងសម្រាប់គម្រោងបន្សាំចំនួន៦ខាងលើ ដោយក្រុមការងារបច្ចេកទេសបន្សាំតាមវិស័យជាមួយការគាំទ្រពីគម្រោងហិរញ្ញប្បទានសហប្រតិបត្តិកាបច្ចេកទេសបញ្ជ្របភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍(TA-MCRDP) កញ្ចប់(Package A)។

### មាតិកា


លទ្ធផលសំខាន់ៗដែលទទួលបានក្រោមយន្តការគាំទ្រ............ ទំព័រ ៣
ការវាយតម្លៃសមត្ថភាពពាក់កណ្តាលអាណត្តិសម្រាប់ក្រសួង.... ទំព័រ ៥
ក្រុមអង្គការសង្គមស៊ីវិលពិនិត្យមើលឡើងវិញអំពីផែនការមេ...... ទំព័រ ៥
សកម្មភាពបណ្តុះបណ្តាលរបស់លេខាធិការដ្ឋាន................... ទំព័រ ៥





*ឯកឧត្តម ឯ វុឌ្ឍី (កណ្តាល) អគ្គលេខាធិការរងក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព បណ្ឌិត តូច ច័ន្ទក្រឹស្នា (ឆ្វេង) អគ្គនាយករង នៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បណ្ឌិត Peter-John Meynell (ស្តាំ) ប្រធានដឹកនាំក្រុមការងារគម្រោង MCRDP កញ្ចប់ (Package A)*

គម្រោងបន្សាំ គឺជាគំនិតផ្តួចផ្តើមពហុវិស័យឆ្លើយតបនឹងវិស័យអាទិភាពដែលបានកំណត់ក្រោមកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR) រួមមានវិស័យកសិកម្ម ធនធានទឹក ការអភិវឌ្ឍទីក្រុង និងការដឹកជញ្ជូន។ ការសិក្សាលម្អិតលទ្ធភាពនីមួយៗ ត្រូវបានពិគ្រោះយោបល់ជាមួយក្រសួងស្ថាប័នពាក់ព័ន្ធក្នុងបណ្តាខេត្តដែលពាក់ព័ន្ធ និងសហគមន៍មូលដ្ឋាន។ ការវិភាគ និងវិធានការបបម ដើម្បីដោះស្រាយការការពារសុវត្ថិភាពសង្គម បរិស្ថាន យេនឌ័រ និងសង្គម ត្រូវបានបញ្ចូលទៅក្នុងការសិក្សានេះ។

អ្នកចូលរួមនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលតំណាងឱ្យវិស័យនីមួយៗ បានចូលរួមការពិភាក្សាក្នុងក្រុមដើម្បី

ចាត់អាទិភាពគម្រោង តាមរយៈការដាក់ពិន្ទុផ្អែកលើលក្ខណៈវិនិច្ឆ័យរបស់មូលនិធិអាកាសធាតុអន្តរជាតិ និងការពិភាក្សាក្នុងក្រុមលើបញ្ហាបច្ចេកទេស។

គម្រោងទាំងបីខាងក្រោមទទួលបានលទ្ធផលពិន្ទុខ្ពស់ជាងគេ៖

**គម្រោងបន្សាំខ្សែក្រវ៉ាត់បៃតង ភាគខាងលិចក្រុងបាត់ដំបង** គម្រោងនេះត្រូវបានគេរំពឹងថានឹងកាត់បន្ថយការបាត់បង់សេដ្ឋកិច្ច និងសង្គមពីគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត បង្កើន និងធ្វើឱ្យមានស្ថិរភាពដល់ប្រាក់ចំណូលកសិកម្ម និងលើកកម្ពស់ស្ថានភាពសុខុមាលភាពរបស់ប្រជាជននៅខេត្តបាត់ដំបងដែលប្រឈមនឹងការប្រែប្រួលអាកាសធាតុ។ លទ្ធផលរបស់គម្រោង គឺបរិស្ថានដែលធន់នឹងអាកាសធាតុ និងសហគមន៍នៅក្រុង និងទីប្រជុំជនក្នុងឃុំចំនួនប្រាំបីនៃក្រុងបាត់ដំបង។



*លោក ណុំ សោភារិទ្ធ អ្នកឯកទេសជាតិផ្នែកកសាងគម្រោងបន្សាំនៃគម្រោង MCRDP កញ្ចប់ (Package A) ធ្វើបទបង្ហាញពីគម្រោងបន្សាំខ្សែក្រវ៉ាត់បៃតងភាគខាងលិច ក្រុងបាត់ដំបង*

**គម្រោងហេដ្ឋារចនាសម្ព័ន្ធ និងកសិកម្មឆ្លាតខាងអាកាសធាតុ (ខេត្តត្បូងឃ្មុំ)** គម្រោងនេះ នឹងកាត់បន្ថយភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុរបស់ប្រជាជនជាពិសេសក្រុមងាយរងគ្រោះបំផុត និងប្រព័ន្ធធម្មជាតិ និងសង្គមសំខាន់ៗនៅខេត្តត្បូងឃ្មុំ។ លទ្ធផលនៃគម្រោងនេះ នឹងបង្កើនភាពធន់នឹងអាកាសធាតុនៃជីវភាពរស់នៅតាមជនបទក្នុងស្រុកចំនួន៣ដែលងាយរងគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត (ស្រុកតំបែ ត្បូងឃ្មុំ និងក្រូចឆ្មារ) នៃខេត្តត្បូងឃ្មុំ។

**គម្រោងកែលម្អជីវភាពរស់នៅធន់នឹងអាកាសធាតុ (ខេត្តកំពង់ឆ្នាំង)** គម្រោងនេះ នឹងជួយបង្កើនភាពធន់ដល់ប្រជាជនដែលងាយរងគ្រោះ និងប្រព័ន្ធ ធម្មជាតិ និងសង្គមសំខាន់ៗនៅស្រុកកំពង់លែង ខេត្តកំពង់ឆ្នាំង ស្របតាមផែនការយុទ្ធសាស្ត្រឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុកម្ពុជា (២០១៤-២០២៣)។ លទ្ធផលរបស់គម្រោងនេះ នឹងបង្កើនភាពធន់នឹងអាកាសធាតុនៃខ្សែសង្វាក់តម្លៃកសិកម្ម (ផលិតកម្ម ដឹកជញ្ជូន ទីផ្សារ និងសេវាកម្មស្រុកកំពង់លែង)។

គម្រោង៣ផ្សេងទៀត ត្រូវបានពិចារណារួមមាន៖

**គម្រោងប្រព័ន្ធធារាសាស្ត្របន្សាំនឹងការប្រែប្រួលអាកាសធាតុដំណាក់ឈើក្រំ (ខេត្តបាត់ដំបង និងពោធិ៍សាត់)**គម្រោងនេះនឹងរួមចំណែកកាត់បន្ថយភាពងាយរងគ្រោះដើម្បីធ្វើឱ្យប្រសើរឡើងជីវភាពរស់នៅ និងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនចំនួនជិត ៧៥ ០០០នាក់ដែលរស់នៅក្នុងតំបន់ទីជម្រាល និងទំនាបក្នុងខេត្តពោធិ៍សាត់ និងខេត្តបាត់ដំបង។ លទ្ធផលរបស់គម្រោងនេះ នឹងធ្វើឱ្យសហគមន៍ធន់នឹងអាកាសធាតុ មានសុវត្ថិភាពជាងមុននៅក្នុងស្រុកវាលវែង ស្រុកភ្នំក្រវាញ ស្រុកបាកាន និងស្រុករុក្ខគិរី។ គម្រោងនេះនឹងត្រូវបានសម្រេចតាមរយៈការធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងធនធានទឹក និងការចែកចាយសម្រាប់ធារាសាស្ត្រស្រោចស្រព និងការស្តារឡើងវិញទីជម្រាល។



*ការពិភាក្សាក្រុមដើម្បីដាក់ពិន្ទុឲ្យគម្រោងវិនិយោគ*

**គម្រោងគ្រប់គ្រងទឹកបន្សាំនឹងការប្រែប្រួលអាកាសធាតុសម្រាប់កសិកម្ម (ខេត្តព្រៃវែង)** លទ្ធផលនៃគម្រោងនេះ នឹងធ្វើឱ្យជីវភាពរស់នៅតាមជនបទកាន់តែមានភាពធន់នឹងអាកាសធាតុក្នុងខេត្តព្រៃវែង។ លទ្ធផលរបស់គម្រោងនេះ គឺពង្រឹងប្រព័ន្ធកសិកម្ម ផ្អែកលើការអនុវត្តការគ្រប់គ្រងធនធានទឹកប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

**គម្រោងសាកល្បងបន្សាំនឹងការប្រែប្រួលអាកាសធាតុតាមរយៈកសិ–ពាណិជ្ជកម្ម (ខេត្តកំពង់ធំ)**គម្រោងផ្តោតលើការណែនាំពីប្រព័ន្ធគ្រប់គ្រងទឹក ដែលមានលក្ខណៈប្រសើរឡើងដោយភ្ជាប់នឹងបច្ចេកវិទ្យាកសិកម្មឆ្លាតខាងអាកាសធាតុ។ លទ្ធផលរំពឹងទុកនៃគម្រោងនេះ គឺបង្កើនប្រាក់ចំណូលពីកសិដ្ឋាន និងជីវភាពរស់នៅជនបទកាន់តែធន់នឹងអាកាសធាតុ។ លទ្ធផលនៃគម្រោងនេះ គឺកសិកម្មឆ្លាតខាងអាកាសធាតុ និងខ្សែសង្វាក់តម្លៃនៅខេត្តកំពង់ធំ។

គម្រោងទាំង៦នេះ ត្រូវបានពិចារណាថាមានគុណភាពល្អ និងមានប្រយោជន៍ក្នុងការគាំទ្រលើការអនុវត្ត។ បច្ចុប្បន្ននេះ នាយកដ្ឋានប្រែប្រួលអាកាសធាតុដោយមានការគាំទ្រពីគម្រោង TA-MCRDP កញ្ចប់ Package A នឹងធ្វើការជាមួយក្រសួងគោលដៅ និងភ្នាក់ងារអនុវត្តដែលមានសក្តានុពល។ ជំហានបន្ទាប់ រួមមានការវាយតម្លៃលក្ខណៈវិនិច្ឆ័យទី៧-ការប្តេជ្ញារបស់ភ្នាក់ងារប្រតិបត្តិដើម្បីគាំទ្រការរៀបចំសំណើគម្រោង និងលក្ខណៈវិនិច្ឆ័យទី៨ស្តីពីចំណាប់អារម្មណ៍ពីភ្នាក់ងារអនុវត្តគម្រោងដែលទទួលស្គាល់ដោយមូលនិធិអាកាសធាតុ។ នៅពេលពិន្ទុត្រូវបានផ្តល់រួចរាល់ ក្រុមការងារធ្វើការជាមួយស្ថាប័នពាក់ព័ន្ធ និងភ្នាក់ងារអនុវត្តគម្រោងដែលទទួលស្គាល់ដោយមូលនិធិអាកាសធាតុដើម្បីបង្កើតទៅជាទស្សនាទាន និងសំណើគម្រោងពេញលេញសម្រាប់គម្រោងអាទិភាពចំនួនពីរ។ សម្រាប់គម្រោងដែលមិនទាន់ត្រូវបានជ្រើសរើស ក្រុមការងារគម្រោង TA-MCRDP កញ្ចប់ Package A នឹងជួយគាំទ្រដល់ក្រសួងដើម្បីស្វែងរកដៃគូអភិវឌ្ឍន៍ និងប្រើប្រាស់ព័ត៌មានសំខាន់ៗនៅក្នុងការសិក្សាលទ្ធភាពទាំងនេះ ដើម្បីស្វែងរកមូលនិធិ និងការអនុវត្ត។

## លទ្ធផលសំខាន់ៗដែលទទួលបានក្រោមយន្តការគាំទ្រសង្គមស៊ីវិល នៃកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ

នៅថ្ងៃអង្គារ ៤កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៨ អង្គការសង្គមស៊ីវិលទាំង១៩ និងអង្គការផ្លែន អន្តរជាតិនៅកម្ពុជាបានរៀបចំសិក្ខាសាលានៅខេត្តកំពត ដើម្បីឆ្លុះបញ្ចាំងពីការអនុវត្តយន្តការគាំទ្រសង្គមស៊ីវិល នៃកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ។ សិក្ខាសាលានេះ ជាឱកាសពិនិត្យមើលឡើងវិញលទ្ធផល ការអនុវត្តល្អៗ អនុសាសន៍ និងវិធានការនានាដែលចាំបាច់ ដើម្បីពង្រីកគម្រោងសង្គមស៊ីវិលនៅមូលដ្ឋានតាមរយៈការសហការជាមួយអង្គការសង្គមស៊ីវិល ដៃគូអភិវឌ្ឍន៍ និងរាជរដ្ឋាភិបាល។

សិក្ខាសាលាបញ្ចប់គម្រោងនេះ ប្រព្រឹត្តឡើងជាលក្ខណៈផ្ទៃក្នុងដែលមានអ្នកចូលរួមសរុបចំនួន៥៥នាក់ (២០នាក់ជាស្ត្រី) រួមមានតំណាងដៃគូអភិវឌ្ឍន៍ អង្គការផ្លែនអន្តរជាតិ តំណាងអង្គការសង្គមស៊ីវិល និងសមាជិកសហគមន៍មូលដ្ឋាន (មេភូមិ សមាជិកគណៈកម្មការប្រើប្រាស់ទឹក និងលោកគ្រូអ្នកគ្រូ) បានចែករំលែកបទពិសោធល្អៗជាច្រើន និងការឆ្លើយតបសំនួរពាក់ព័ន្ធគម្រោងដែលបានអនុវត្តនៅមូលដ្ឋាន។

សិក្ខាសាលានេះ បានឆ្លុះបញ្ចាំងពីការងារដែលបានអនុវត្ត និងសមិទ្ធផលដែលគម្រោងសម្រេចបានគិតចាប់ពីខែកក្កដា ឆ្នាំ២០១៦ នៅពេលដែលអង្គការដៃគូទាំងអស់បានចាប់ផ្តើមអនុវត្តសកម្មភាព នៅទីតាំងគោលដៅ។ សិក្ខាសាលាដែលមានរយៈពេល២ថ្ងៃនេះ មានរួមបញ្ចូលទាំងដំណើរទស្សនកិច្ចសិក្សា បទបង្ហាញពីលទ្ធផល និងការពិនិត្យឡើងវិញគម្រោងរបស់អង្គការសង្គមស៊ីវិល តាមរយៈការពិភាក្សាជាក្រុម និងចែករំលែកនូវមេរៀនល្អៗ ទាក់ទងនឹងរបៀបនៃការសម្របសម្រួលនៅតាមសហគមន៍ របៀប នៃការកែលម្អសមត្ថភាពរបស់សហគមន៍ ដើម្បីកសាងភាពធន់នឹងការប្រែប្រួលអាកាសធាតុ។ អស់រយៈពេល២ឆ្នាំមកនេះ អង្គការសង្គមស៊ីវិល បានចូលរួមចំណែកយ៉ាងសំខាន់ ឆ្លើយតបនឹងការប្រែប្រួលអាកាសធាតុនៅកម្ពុជា។

នៅថ្ងៃចន្ទ ៣កើត ខែចេត្រ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងនៅថ្ងៃទី១៩ ខែមីនា អ្នកចូលរួមបានទៅទស្សនកិច្ចពីរកន្លែង៖

- កន្លែងទី១គឺ កសិដ្ឋានភ្ញាស់កូនមាន់ ដែលបានបង្កើតឡើងដោយអង្គការសុវណ្ណភូមិ ក្នុងស្រុកត្រាំកក់ ខេត្តតាកែវដែលជាផ្នែកមួយនៃគម្រោង "យន្តការគាំទ្រសង្គមស៊ីវិល"។ កសិដ្ឋានភ្ញាស់កូនមាន់នេះ បានផ្តល់ឱ្យសហគមន៍ នូវមាន់ដែលមានសុខភាពល្អធន់នឹងជំងឺដែលកើតឡើងជាញឹកញាប់នៅពេលមានគ្រោះរាំងស្ងួត ឬទឹកជំនន់ និងលើកកម្ពស់ការអនុវត្តវ៉ាក់សាំង និងថ្នាំបង្ការ។ កសិដ្ឋានភ្ញាស់កូនមាន់បំពាក់ដោយទូភ្ញាស់កូនមាន់ចំនួនពីរ។
- កន្លែងទី២ គឺសហគមន៍អេកូទេសចរណ៍ត្រពាំងសង្កែ ស្ថិតក្នុងខេត្តកំពត ដែលទទួលបានជំនួយក្នុងការអភិរក្សព្រៃកោងកាង ធនធានធម្មជាតិ និងហេដ្ឋារចនាសម្ព័ន្ធ ដូចជាស្ពានឈើប្រវែង៥០០ម៉ែត្រពីមជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារ និងស្ត្រីនៅកម្ពុជា។ ស្ពានឈើនៅក្នុងព្រៃកោងកាងគឺជាកត្តាមួយដែលជួយលើកកម្ពស់អភិរក្សព្រៃកោងកាង និងរួមចំណែកជួយរកប្រាក់ចំណូលឱ្យសហគមន៍អាចបន្តការអភិរក្សធនធានជលផល និងសកម្មភាពផ្សេងៗទៀត ដែលអាចផ្តល់ឱ្យប្រជាជនក្នុងតំបន់នេះរកប្រាក់ចំណូលបន្ថែមទៀត តាមរយៈការទាក់ទាញភ្ញៀវទេសចរណ៍មកទស្សនាសហគមន៍។ អ្នកចូលរួមទាំងអស់បានចូលរួមដាំដើមកោងកាងចំនួន៥០ដើម ដើម្បីជាការគាំទ្រដល់គំនិតផ្តួចផ្តើមក្នុងការអភិរក្សព្រៃកោងកាង។

**លទ្ធផលសំខាន់ៗនៃយន្តការគាំទ្រសង្គមស៊ីវិល**




អំឡុងកិច្ចពិភាក្សា អ្នកចូលរួមបានកត់សម្គាល់ថា គម្រោងយន្តការគាំទ្រសង្គមស៊ីវិល បានផ្តល់ជាវិជ្ជមានលើការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុ នៅក្នុងសហគមន៍ ការធ្វើឱ្យប្រសើរឡើងហេដ្ឋារចនាសម្ព័ន្ធនៅក្នុងតំបន់ ដែលងាយរងគ្រោះ បង្កើនជំនាញបច្ចេកទេសដល់កសិករដែលជាអ្នកទទួលផល ផ្តល់នូវប្រាក់ចំណូលតាមរយៈការបង្កើនមុខរបរចម្រុះ និងបង្កើនការផ្គត់ផ្គង់ទឹកស្អាត និងការយល់ដឹងពីអនាម័យនៅតាមផ្ទះ និងសាលារៀនតាមទីជនបទក្នុងប្រទេសកម្ពុជា។

គម្រោងនេះ ក៏បានជម្រុញការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងផែនការវិនិយោគឃុំដែលផ្តោតសំខាន់លើការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។ អ្នកចូលរួមទាំងអស់យល់ថាដំណើរការនៃ

ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ត្រូវការរយៈពេលវែង ខណៈដែល គម្រោងអនុវត្តដោយអង្គការសង្គមស៊ីវិលត្រូវបានផ្តល់មូលដ្ឋានគ្រឹះដ៏រឹងមាំ និងការខិតខំប្រឹងប្រែងជាបន្តបន្ទាប់ទៀត ដើម្បីពង្រឹងសមត្ថភាពសហគមន៍ និងបង្កើនភាពធន់អាកាសធាតុ។

ការឆ្លុះបញ្ចាំងពីអ្នកចូលរួម៖

### ភាពទាក់ទង

- បទអន្តរាគមន៍របស់គម្រោង គឺផ្អែកលើការវាយតម្លៃហានិភ័យ និងភាពងាយរងគ្រោះរបស់សហគមន៍ដោយប្រើឧបករណ៍ (VRA) ដូច្នេះវាអាចបំពេញនូវអ្វីដែលសហគមន៍គិតថាមានសារៈសំខាន់ និងចាំបាច់យកចិត្តទុកដាក់ជាពិសេសទៅលើតម្រូវការរបស់ស្ត្រី និងកុមារ។
- ការរៀបចំសកម្មភាពរបស់គម្រោងស្របនឹងផែនការអភិវឌ្ឍន៍ជាតិ និងក្រសួងនានាដែលផ្តោតសំខាន់លើការប្រែប្រួលអាកាសធាតុ

### ប្រសិទ្ធផល

- អង្គការសង្គមស៊ីវិលបានបង្កើនការប្រើប្រាស់មូលនិធិប្រកបដោយប្រសិទ្ធភាព តាមរយៈការរៀបចំផែនការបានត្រឹមត្រូវ មានការសហការបានល្អជាមួយអាជ្ញាធរមូលដ្ឋាន និងវិស័យឯកជន ដើម្បីឆ្លើយតបនៅពេលដែលមានបញ្ហាកើតឡើង។ សកម្មភាពនេះក៏មានការគាំទ្រពីអ្នកស្ម័គ្រចិត្តក្នុងសហគមន៍ រួមទាំងយុវជនដែលបានចូលរួមជាមួយគម្រោង។

### ប្រសិទ្ធភាព

- ដោយការអនុវត្តគម្រោងមានរយៈពេលខ្លី វាមានការពិបាកក្នុងការវាស់វែងផលប៉ះពាល់វិជ្ជមាន និងអវិជ្ជមានពីការអនុវត្តសកម្មភាពរបស់គម្រោង។
- សហគមន៍យល់ថា ពួកគាត់យល់ដឹងច្រើនជាងមុនអំពីសកម្មភាពបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងមានដំណោះស្រាយបាននៅពេលដែលមានបញ្ហាបណ្តាលមកពីការប្រែប្រួលអាកាសធាតុកើតឡើង។
- អង្គការសង្គមស៊ីវិល អាចសម្រេចនូវគោលដៅរយៈពេលខ្លីដែលបានកំណត់

### និរន្តរភាព

- ដោយសារការអនុវត្តគម្រោងត្រូវតែអនុវត្តតាមកាលកំណត់ ដូច្នេះដើម្បីឱ្យគម្រោងមាននិរន្តរភាព គឺត្រូវតែមានការលើកទឹកចិត្ត និងចូលរួមយ៉ាងខ្លាំងពីសំណាក់សហគមន៍ និងអាជ្ញាធរមូលដ្ឋាន។
- ដើម្បីធានាបាននូវភាពជាម្ចាស់របស់សហគមន៍ អង្គការសង្គមស៊ីវិល បានអញ្ជើញ។

អាជ្ញាធរមូលដ្ឋាន និងសមាជិកពីសហគមន៍ឱ្យចូលរួមក្នុងដំណើការរៀបចំផែនការ និងការអនុវត្តគម្រោង។ គម្រោងនេះបានចូលរួម និងគាំទ្រដោយថ្នាក់ដឹកនាំចំនួន៦០នាក់មកពីគ្រប់មជ្ឈដ្ឋាន ហើយជាមធ្យម៥៥%នៃសមាជិកគឺជាស្ត្រី។

អង្គការសង្គមស៊ីវិល ដែលបានចូលរួមបានផលិតឯកសារចំណេះដឹងមួយចំនួន ដែលគាំទ្របច្ចេកទេសពីអង្គការ ផ្លែនអន្តរជាតិ និងធនាគារADB។ ឯកសារវីដេអូ និងឯកសារផ្សព្វផ្សាយលើកកម្ពស់ការយល់ដឹងរួមមាន៖ ភាពធន់នៅតំបន់ឆ្នេរ កសិកម្មឆ្លាតខាងអាកាសធាតុ ការផ្គត់ផ្គង់ទឹក និងការរៀបចំផែនការក្រុងដែលធន់នឹងអាកាសធាតុ យេនឌ័រនិងការអភិវឌ្ឍ ការបញ្ជ្រាបការបន្សាំដែលមានប្រសិទ្ធភាព និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅក្នុងអង្គការសង្គមស៊ីវិលនិងប្រធានបទផ្សេងៗទៀត។ ឯកសារចំណេះដឹងទាំងនេះ នឹងត្រូវបានដាក់បង្ហោះក្នុងពេលឆាប់ៗនេះលើគេហទំព័រ www.spcrcambodia.org

អ្នកចូលរួម បានគូសបញ្ជាក់នូវអនុសាសន៍មួយចំនួនស្តីពីកិច្ចប្រឹងប្រែងក្នុងការងារបន្សាំនាពេលអនាគត រួមមាន៖

- បង្កើនសកម្មភាពជួយដល់អង្គការសង្គមស៊ីវិលដើម្បីចូលរួមយ៉ាងសកម្មនៅក្នុងកម្មវិធី និងបណ្តាញជាតិស្តីពីការប្រែប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។
- កិច្ចសហការជិតស្និទ្ធរវាងអង្គការសង្គមស៊ីវិលនិងរដ្ឋាភិបាលដើម្បីកែលម្អ និងអនុវត្តតាមគោលការណ៍ជាតិណែនាំស្តីពីការបញ្ជ្រាបការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ
- កិច្ចសហប្រតិបត្តិការនិងការសម្របសម្រួល បន្ថែមទៀតរវាងអង្គការសង្គមស៊ីវិល និងរដ្ឋាភិបាលថ្នាក់ក្រោមដើម្បីបង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីដាក់បញ្ចូល ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយទៅក្នុងផែនការអភិវឌ្ឍមូលដ្ឋាន ជាពិសេសនៅតំបន់ជនបទ និងតំបន់ដាច់ស្រយាល។
- បង្កើនការគាំទ្រផ្នែកបច្ចេកទេសពីមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងមន្ទីរបរិស្ថាន និងអង្គការសង្គមស៊ីវិលដើម្បីសាកល្បងនិងអនុវត្តបច្ចេកទេសធន់នឹងអាកាសធាតុថ្មី។
- បង្កើនធនធានសម្រាប់ថ្នាក់ក្រោមជាតិ – ជាពិសេសថ្នាក់ឃុំ – ដើម្បីបង្កើតនិងអនុវត្តដំណោះស្រាយបន្សាំដែលសមស្រប ទៅនឹងតំបន់របស់ពួកគេ – ដោយមានការចូលរួមពីអង្គការ សង្គមស៊ីវិល។
- បង្កើនកិច្ចខិតខំប្រឹងប្រែងក្នុងចំណោមម្ចាស់ជំនួយដែលមានស្រាប់ និងដៃគូអភិវឌ្ឍន៍ដើម្បីពង្រីកកម្មវិធី ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយនៅក្នុងតំបន់ងាយរងគ្រោះ និងតំបន់គ្រោះមហន្តរាយ។
- ការវិនិយោគកាន់តែច្រើនឡើងពីសំណាក់ម្ចាស់ជំនួយ និងដៃគូអភិវឌ្ឍន៍សម្រាប់កម្មវិធីការបន្សាំនឹងការប្រែប្រួលអាកាសធាតុរយៈពេលវែង រួមជាមួយនឹងការបន្តការកសាងសមត្ថភាពអង្គការសង្គមស៊ីវិលដើម្បីគាំទ្រដល់ថ្នាក់ក្រោមជាតិក្នុងការអនុវត្តការតាមដាន ត្រួតពិនិត្យ វាយតម្លៃ និងការផ្តល់យោបល់បច្ចេកទេស ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ។

## ការវាយតម្លៃសមត្ថភាពពាក់កណ្ដាលអាណត្តិសម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

នៅថ្ងៃពុធ ១៤កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ត្រូវនឹងនៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៨ គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស កញ្ចប់A បានសម្របសម្រួលកិច្ចប្រជុំតុមូលជាមួយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីពិនិត្យមើលឡើងវិញនូវវឌ្ឍនភាពនៃការកសាងសមត្ថភាពស្ថាប័ន សម្រាប់ការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ កម្រងសំនួរ ៧S អំពីយុទ្ធសាស្ត្រ រចនាសម្ព័ន្ធ ភាពដឹកនាំ ប្រព័ន្ធ បុគ្គលិក ជំនាញ និងការគាំទ្រ ដែលអាចគូសចេញជាដ្យាក្រាមពិន្ទុ ត្រូវបានពិភាក្សា ហើយ ខាងលើនេះ ជាដ្យាក្រាម៧Sរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលត្រូវបានប្រៀបធៀបពីឆ្នាំ២០១៥ ដល់ឆ្នាំ២០១៧។ ព័ត៌មាននេះ អាចជួយដល់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងការកំណត់អាទិភាព សម្រាប់បង្កើនសមត្ថភាពបន្សាំនៅក្នុងស្ថាប័ន គោលនយោបាយ និងកម្មវិធី ព្រមទាំងជួយឱ្យដឹងពីតម្រូវការគាំទ្រពីកម្មវិធីយុទ្ធសាស្ត្រសម្រាប់ភាពធន់នឹងអាកាសធាតុ (SPCR) ឬកម្មវិធីផ្សេងៗទៀត។




## ក្រុមអង្គការសង្គមស៊ីវិលពិនិត្យមើលឡើងវិញអំពីផែនការមេ ស្ដីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ

នៅថ្ងៃពុធ ១៤រោច ខែមាឃ ឆ្នាំរកា នព្វស័កព.ស. ២៥៦១ត្រូវនឹងនៅថ្ងៃទី១៤ខែកុម្ភៈឆ្នាំ២០១៨គម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ ទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ បានធ្វើបទបង្ហាញផែនការមេស្ដីពីយេនឌ័រ និងការប្រែប្រួលអាកាសធាតុ (២០១៨-២០៣០) ដល់ក្រុមបច្ចេកទេសមកពីអង្គការសង្គមស៊ីវិល និងអង្គការមិនមែនរដ្ឋាភិបាល ដែលមានឈ្មោះថា ក្រុមសកម្មភាពរួមសម្រាប់ការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ (JAG DRR / CCA)។ អ្នកចូលរួមជាសមាជិកអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិចំនួន១៧របស់ក្រុម JAG DRR / CCA ដែលជាទីភ្នាក់ងារបច្ចេកទេសផ្ដល់អនុសាសន៍ និងការគាំទ្របច្ចេកទេស ដល់គំនិតផ្ដួចផ្ដើមនានារបស់រដ្ឋាភិបាលលើការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ អង្គការសង្គមស៊ីវិល បានរួមចំណែកក្នុងការអភិវឌ្ឍផែនការមេ តាមរយៈការពិគ្រោះយោបល់ចំនួនបីដងរួមទាំងវគ្គមុនៗនៅក្នុងខេត្តសៀមរាប និងរាជធានីភ្នំពេញ។




## សកម្មភាពបណ្ដុះបណ្ដាលរបស់លេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

លទ្ធផលទី១នៃគម្រោងTA៨១៧៩ កញ្ចប់C របស់លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គជអប)គឺ “សមត្ថភាពស្ថាប័ន និងបច្ចេកទេសរបស់រដ្ឋបាលថ្នាក់ក្រោមជាតិក្នុងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុ ត្រូវបានធ្វើឱ្យប្រសើរឡើង”។ យោងតាមការប្ដេជ្ញាខាងលើនេះ កម្មវិធីបណ្ដុះបណ្ដាលយ៉ាងទូលំទូលាយ បាននិងកំពុងដំណើរការមកដល់បច្ចុប្បន្ននេះមានវគ្គបណ្ដុះបណ្ដាលចំនួន២៤ផ្នែកត្រូវបានរៀបចំឡើង។

កម្មវិធីបណ្ដុះបណ្ដាលត្រូវបានរៀបរៀងជា០៤ម៉ូឌុល៖

- ការណែនាំអំពីគម្រោង រួមមានការប្រែប្រួលអាកាសធាតុនៅកម្ពុជា និងការបន្សាំ (ត្រូវបានបញ្ចប់ក្នុងឆ្នាំ២០១៧)
- ការវិភាគភាពងាយរងគ្រោះ និងឧបករណ៍ជ្រើសរើស

ហានិភ័យ អាកាសធាតុជាផ្នែកមួយនៃដំណើរការកសាងផែនការ និងថវិកា (បច្ចុប្បន្នកំពុងដំណើរការ)

- ភាពធន់នឹងអាកាសធាតុក្នុងការរៀបចំនិងអនុវត្តគម្រោង (ទើបចាប់ផ្តើមនាពេលថ្មីៗនេះ) និង
- ការពិនិត្យ តាមដាន និងវាយតម្លៃសមត្ថភាពបន្សាំ (គ្រោងចាប់ផ្តើមនៅខែមិថុនា ឆ្នាំ២០១៨)

បទបង្ហាញ និងការសម្របសម្រួល ត្រូវបានធ្វើឡើងដោយក្រុមទីប្រឹក្សាបច្ចេកទេស ជាមួយមន្ត្រីនៃលេខាធិការដ្ឋាន គ.ជ.អ.ប មន្ទីរជំនាញព្រមទាំងមន្ត្រីបង្គោលផ្សេងៗទៀត។

ក្នុងពេលបណ្តុះបណ្តាល អ្នកចូលរួមមិនត្រឹមតែបានរៀនសូត្រពីអ្នកសម្របសម្រួលប៉ុណ្ណោះទេ ថែមទាំងបានរៀនសូត្រពីគ្នាទៅវិញទៅមកផងដែរ។ ជាមួយគ្នានោះដែរ អ្នកសម្របសម្រួលក៏បានរៀនសូត្រពីអ្នកចូលរួម ទាក់ទងនឹងការយល់ដឹងនៅតំបន់មូលដ្ឋាន និងវិស័យការងាររបស់អ្នកចូលរួម។ ការពិភាក្សាពេញអង្គ និងក្រុមពិភាក្សា បានផ្តល់នូវឱកាសចែករំលែកចំណេះដឹង និងបទពិសោធ។ ដូច្នេះសកម្មភាពបណ្តុះបណ្តាលបានផ្សារភ្ជាប់នឹងការរៀបចំឯកសារចំណេះដឹង ជាមួយការជ្រើសរើស និងកំណត់វិសាលភាពគម្រោងសាកល្បង។

តំណាងរដ្ឋបាលថ្នាក់ក្រោមជាតិបានយល់ដឹង និងកោតសរសើរអំពីគោលបំណងនៃ គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការបច្ចេកទេស TA៨១៧៩ កញ្ចប់ C និងលេខាធិការដ្ឋាន គ.ជ.អ.ប រួមមានរបៀបអនុវត្ត និងផលប្រយោជន៍ច្រើនយ៉ាងនៃការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ និងការកាត់បន្ថយហានិភ័យគ្រោះមហន្តរាយ ទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ពួកគាត់ត្រូវបានផ្តល់ព័ត៌មានគ្រប់គ្រាន់ អំពីទីកន្លែងជាក់លាក់នានាដែលរងសម្ពាធ និងផលប៉ះពាល់ពីការប្រែប្រួលអាកាសធាតុ ប៉ុន្តែពួកគាត់ទទួលបានព័ត៌មានតិចតួច អំពីជម្រើសបន្សាំនឹងការប្រែប្រួលអាកាសធាតុព្រមទាំងកាលានុវត្តភាពនានា។



វគ្គបណ្តុះបណ្តាលទទួលបាននូវការកោតសរសើរ និងការចាប់អារម្មណ៍ពីអ្នកចូលរួម តាមរយៈបញ្ជីសំនួរនៅពេលបញ្ចប់វគ្គបណ្តុះបណ្តាលនីមួយៗ។

ការកសាងសមត្ថភាព ស្តីពីការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិនៅថ្ងៃអង្គារ ៧កើត និងថ្ងៃពុធ ៨កើត ខែមាឃ ឆ្នាំរកា នព្វស័កព.ស. ២៥៦១ ត្រូវនឹងថ្ងៃទី២៣-២៤ ខែមករា ឆ្នាំ២០១៨ គម្រោងការបញ្ជ្រាបភាពធន់នឹងអាកាសធាតុទៅក្នុងការរៀបចំផែនការអភិវឌ្ឍន៍ កញ្ចប់ C បានរៀបចំវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការប្រើប្រាស់ឧបករណ៍ដើម្បីវិភាគហានិភ័យអាកាសធាតុក្នុងដំណើរការរៀបចំផែនការឃុំ និងថវិកា។ នេះ គឺជាវគ្គបណ្តុះបណ្តាលលើកទី២ជាមួយអ្នកតំណាងខេត្តចំនួន១២មកពីក្រសួងស្ថាប័នពាក់ព័ន្ធ។ គោលបំណងនៃវគ្គបណ្តុះបណ្តាល គឺបង្កើនការយល់ដឹងរបស់រដ្ឋបាលថ្នាក់ក្រោមជាតិលើការប្រើប្រាស់ឧបករណ៍វិភាគអាកាសធាតុ និងថវិកាដើម្បីអភិវឌ្ឍគម្រោងបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ វគ្គបណ្តុះបណ្តាលនេះ ក៏រួមចំណែកបង្កើនការយល់ដឹងលើប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃនៅថ្នាក់ក្រោមជាតិដោយប្រើប្រាស់យេនឌ័រ និងលក្ខណៈវិនិច្ឆ័យផ្សេងទៀតសម្រាប់ជ្រើសរើសគម្រោងសាកល្បងដើម្បីអនុវត្តនៅតាមខេត្តគោលដៅ។

**ព័ត៌មានបន្ថែម៖**

ឯកឧត្តម សាស្ត្រាចារ្យ បណ្ឌិត សាបូ អូហ្សាណូ រដ្ឋលេខាធិការក្រសួងបរិស្ថាន និងជាប្រធានសម្របសម្រួលកម្មវិធី
លោក មាស សុផល នាយកដឹកនាំកម្មវិធី
លោក អ៊ូ ច័ន្ទធារិទ្ធ ប្រធានគ្រប់គ្រងកម្មវិធី
អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍ដោយចីរភាព
នាយកដ្ឋានប្រែប្រួលអាកាសធាតុ
អគារមរតកតេជោ ឡូត៍លេខ៥០៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ប្រទេសកម្ពុជា
ទូរស័ព្ទ៖ ៨៥៥ ២៣ ៥៣១៤ ៧៧៧
អ៊ីម៉ែល៖ adbspcrta8179@gmail.com
គេហទំព័រ៖ http://www.spcrcambodia.org/